**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុមប្រឹក្សា
កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
អគ្គលេខាធិការដ្ឋាន
លេខ:០១៩/០៩ របកកចយ

# របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែកក្កដាឆ្នាំ២០០៩របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ កក្កដា ឆ្នាំ២០០៩ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បាន ដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្មដែលបានកំណត់ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ហើយសម្រេចបាន នូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

## ១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌

### ក. ការងាររដ្ឋបាល

- ផ្ញើលិខិតលេខ ០៣៧/០៩ លស.កកចយ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ ជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្តីពីសំណើសុំការអនុញ្ញាតជូន ឯកឧត្តម សក់ សេដ្ឋា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ដើម្បីចូលរួមក្នុងទស្សនកិច្ចសិក្សាស្តីពីការងារអំប៊ុស្មាន់ នៅសាធារណៈរដ្ឋកូរ៉េខាងត្បូង ចាប់ពីថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០០៩ ដល់ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩ ។

- ផ្ញើលិខិតលេខ ០៣៧/០៩ លស.កកចយ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ ជូនឯកឧត្តម ឱម យ៉ិនទៀង ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ស្តីពីសំណើសុំការអនុញ្ញាតជូន ឯកឧត្តម សរ សម្បត្តិ សមាជិក អចិន្ត្រៃយ៍នៃអង្គភាពប្រឆាំងអំពើពុករលួយ ដើម្បីចូលរួមក្នុងទស្សនកិច្ចសិក្សាស្តីពីការងារអំប៊ុស្មាន់នៅ សាធារណៈរដ្ឋកូរ៉េខាងត្បូងចាប់ពីថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០០៩ ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩ ។

- ផ្ញើលិខិតលេខ ០៣៧/០៩ លស.កកចយ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ ជូនឯកឧត្តម ឱម យ៉ិនទៀង ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ស្តីពីសំណើសុំការអនុញ្ញាតជូន ឯកឧត្តម ម៉ក់ សម្បត្តិ សមាជិក គណកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដើម្បីចូលរួមក្នុងទស្សនកិច្ចសិក្សាស្តីពីការងារអំប៊ុស្មាន់នៅសាធារណៈរដ្ឋកូរ៉េខាងត្បូង ចាប់ពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៩ ដល់ថ្ងៃទី៣១ ខែកក្កដាឆ្នាំ២០០៩ ។

- ផ្ញើលិខិតលេខ ០៣៧/០៩ លស.កកចយ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ ជូនឯកឧត្តម អង្គ វង្សវឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ស្តីពីសំណើសុំការអនុញ្ញាតជូន ឯកឧត្ដម ច័ន្ទ មនោ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុក្រសួងយុត្តិធម៌ ដើម្បីចូលរួមក្នុងទស្សនកិច្ចសិក្សា ស្តីពី

ការងារអំប៊ុស្មាន់នៅសាធារណៈរដ្ឋកូរ៉េខាង ត្បូងចាប់ពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៩ ដល់ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩ ។

- ផ្ញើលិខិតលេខ ០៣៧/០៩ លស.កកចយ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ ជូន ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីសំណើសុំការអនុញ្ញាតជូនឯកឧត្តម ច័ន្ទ តានី រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីចូលរួមក្នុងទស្សនកិច្ចសិក្សា ស្តីពីការងារអំប៊ុស្មាន់នៅសាធារណៈរដ្ឋកូរ៉េខាងត្បូង ចាប់ពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៩ ដល់ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩

- ផ្ញើលិខិតលេខ ០៣៨/០៩ លស.កកចយ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៩ ជូនឯកឧត្តម លឹម សំកុល ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅសាធារណៈរដ្ឋកូរ៉េខាងត្បូង ស្តីពី សំណើសុំជួយសម្រួលការងារទស្សនកិច្ចសិក្សារបស់គណៈ-ប្រតិភូនៃរាជរដ្ឋាភិបាលកម្ពុជា ស្តីពីការងារអំប៊ុស្មាន់ នៅសាធារណៈរដ្ឋកូរ៉េខាងត្បូង ចាប់ពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ ដល់ថ្ងៃទី៣១ខែកក្កដា ឆ្នាំ ២០០៩ ។

- ផ្ញើលិខិតលេខ ០៤១/០៩ លស.កកចយចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៩ ជូនឯកឧត្តម ឧបនាយករដ្ឋ មន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីសំណើសុំផ្ញើលិខិតឆ្លងដែនផ្លូវការជូន មន្ត្រី និងថ្នាក់ដឹកនាំនៃ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងកំណត់ទូតជូនគណៈប្រតិភូនៃទស្សនៈ កិច្ចសិក្សាស្វែងយល់អំពីប្រព័ន្ធអំប៊ុស្មាន់ (Ombudsman) នៅទីក្រុងសេអ៊ូលប្រទេសសាធារណៈរដ្ឋកូរ៉េខាងត្បូង (South Korea)

- ផ្ញើលិខិតលេខ ០៤២/០៩ លស.កកចយ ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៩ ជូន Mr.Ho Se-Hoon (Mayor of Seoul Metropolitan Government) Republic of Korea ស្តីពីRequest an Appointment on 30 July 2009 at 9:30 am, list of the delegation of Cambodia Government of study tour

- ផ្ញើលិខិតលេខ ០៤៣/០៩ លស.កកចយ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩ ជូនឯកឧត្តម ប្រាក់ សុខុន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការផ្ញើ របាយការណ៍ដំណើរការ នៃកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ជូន សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ។

- ផ្ញើលិខិតលេខ ០៤៤/០៩ លស.កកចយ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩ ជូនឯកឧត្តម ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ ស្តីពីធាតុចូលនៃវិស័យកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌សម្រាប់ការ រៀបចំផែនការអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩ -២០១៣ ។

- ផ្ញើលិខិតលេខ ០៤៥/០៩ លស.កកចយ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីសំណើរសុំបញ្ជូនឈ្មោះ មន្ត្រីនៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដែលត្រូវតម្លើងប្រាក់កំរិតមុខងារ ។

- ផ្ញើលិខិតលេខ ០៤៦/០៩ លស.កកចយ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩ ជូនឯកឧត្តម អគ្គលេខាធិការរងរាជរដ្ឋាភិបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីសំណើរសុំលិខិតបេសកកម្ម និងប័ណ្ណដើរផ្លូវសម្រាប់ថ្នាក់ដឹកនាំ ប្រធានផ្នែក អនុប្រធានផ្នែក និងមន្ត្រីអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដើម្បីចុះទៅធ្វើផែនការយុទ្ធសាស្ត្រ របស់អគ្គលេខាធិការដ្ឋាន នៅខេត្តកោះកុង ។

- ផ្ញើលិខិតលេខ ០៤៧/០៩ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីសំណើអញ្ជើញគណៈប្រតិភូចូលរួមប្រជុំពិភាក្សាការងារ ពីដំណើរទស្សនៈកិច្ចសិក្សា ស្តីពីការងារអំប៊ុស្មាន់ នៅសាធារណៈរដ្ឋកូរ៉េ នៅថ្ងៃព្រហស្បតិទី ២៣ ខែកក្កដា ឆ្នាំ២០០៩ វេលាម៉ោង ១៥ៈ០០ ។

- ផ្ញើលិខិតលេខ ០៤៨/០៩ លស.កកចយ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ជូនឯកឧត្តម ម៉ក់ សម្បត្តិ អនុប្រធានគណកម្មាធិកាសិទ្ធិមនុស្សកម្ពុជា ឯកឧត្តម ច័ន្ទ តានី រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តម សរ សម្បត្តិ សមាជិកអចិន្ត្រៃយ៍ នៃអង្គភាពប្រឆាំងអំពើពុករលួយ ឯកឧត្តម ច័ន្ទ មនោ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុក្រសួងយុត្តិធម៌ ឯកឧត្តម សក់ សេដ្ឋា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ស្តីពីសំណើសុំជូនព័ត៌ មានអំពីដំណើរអញ្ជើញ និងត្រឡប់ មកវិញ (ភ្នំពេញ-សេអ៊ូល-ភ្នំពេញ) របស់គណៈប្រតិភូនៃដំណើទស្សនៈកិច្ចសិក្សា ស្តីពីការរៀបចំទស្សនទានអំពីអំប៊ុស្មាន់ (Ombudsman) នៅកម្ពុជា។

- ផ្ញើលិខិតលេខ ០៤៩/០៩ លអ.កកចយ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ អញ្ជើញសមាជិកចូលរួម ប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ វេលាម៉ោង ១៤ៈ៣០នាទីរសៀល ។

- ផ្ញើលិខិតអញ្ជើញលេខ ០៥០/០៩ លអ.កកចយ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ជូនឯកឧត្តម ជីវ កេង ប្រធានសាលាដំបូងរាជធានីភ្នំពេញ និងជាសមាជិកឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ឯកឧត្តម ទេព ដារ៉ុង ប្រធានរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ឯកឧត្តម ជីវ សុងហាក់ ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម ហេង ហាក់ នាយក នៃនាយកដ្ឋានពន្ធនាគា ឯកឧត្តម អ៊ុក សាវុធ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងជាសមាជិកក្រុមប្រឹក្សានៃអង្គចៅក្រម ឯកឧត្តម សូ ចន្ទី អគ្គាធិការនៃអគ្គាធិការដ្ឋាន ឯកឧត្តម កើត សេកាណូ អគ្គលេខាធិការរាជបណ្ឌិតសភាវិជ្ជជីវៈតុលាការ ឯកឧត្តម យូ ប៊ុនឡេង ប្រធានសាលាឧទ្ធរណ៍ និងជាសមាជិកឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ឯកឧត្តម គង់ ស្រឹម សមាជិកក្រុមប្រឹក្សាវិន័យ និងជាសមាជិក ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ដើម្បីអញ្ជើញចូលរួម ប្រជុំដោះស្រាយបញ្ហាប្រឈមក្នុងវិស័យតុលាការនៅ ថ្ងៃពុធ ទី០៥ ខែសីហារ ឆ្នាំ២០០៩ វេលាម៉ោង ៩ៈ០០ ព្រឹក (ដោយយោងអនុសាសន៍របស់ឯកឧត្តម ឧបនាយក រដ្ឋមន្ត្រី សុខ អាន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី)។

- ផ្ញើលិខិតលេខ ០៥១/០៩ លស.កកចយ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩ ជូន ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីសំណើសុំបញ្ជូនមន្ត្រី ០១ រូបដើម្បីចូលរួមវគ្គ បណ្តុះបណ្តាល ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នៅក្នុងសេដ្ឋកិច្ចពិភពលោក នៅទីក្រុងស្តុកខុម (Stockholm) ប្រទេសស៊ុយអែត (Sweden)

- ផ្ញើលិខិតលេខ ០៥២/០៩ លស.កកចយ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩ ជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រត្តិបត្តិអន្តរជាតិ ស្តីពីសំណើសុំចាត់មន្ត្រីរបស់អគ្គលេខាធិការដ្ឋាននៃ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ០១រូប ដើម្បីទៅសិក្សាថ្នាក់អនុបណ្ឌិត ផ្នែកច្បាប់ពាណិជ្ជកម្ម និងសេដ្ឋកិច្ចអន្តរជាតិនៅទីក្រុងហ្វូគុយកា-កិន(Fukuoka-ken) ប្រទេសជប៉ុន (Japan) ។

- ផ្ញើលិខិតលេខ ០៥៣/០៩ លស.កកចយ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីសំណើរសុំធ្វើលិខិតឆ្លងដែនផ្លូវការ និងចេញកំណត់ទូតជូនលោក គង់ ផល្លៈ អនុប្រធានផ្នែក

កំណែទម្រង់ច្បាប់ នៃអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិ ប្រហាក់ប្រហែលនៅក្នុងសេដ្ឋកិច្ចពិភពលោក នៅទីក្រុងស្តុកខុម ប្រទេសស៊ុយអែត ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៩ ដល់ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩។

- បានទទួលលិខិត ១៤៩ រប.៩២១/០៩ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ពីសាលាដំបូងរាជធានីភ្នំពេញ ស្តីពីរបាយការណ៍ប្រចាំឆមាសឆ្នាំ២០០៩ ស្តីអំពីសកម្មភាពការងារគិតចាប់ពីថ្ងៃទី១៦ ខែវិច្ឆិការ ឆ្នាំ២០០៨ ដល់ថ្ងៃទី១៥ ខែ ឧសភា ឆ្នាំ២០០៩ ។

-បានទទួលលិខិតលេខ ១៤ ដនស/អរប/រប ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីរបាយការណ៍បូកសរុបលទ្ធផលអនុវត្តការងារ ៩ខែ ដើមឆ្នាំ ២០០៩ និងទិសដៅបន្ត ។

-បានទទួលលិខិតលេខ ៣៨៤៨ សហវ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៩ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីសំណើសុំអនុញ្ញាតជួបពិភាក្សាអំពីការវាយតម្លៃផ្នែកហិរញ្ញវត្ថុ និងការត្រួតពិនិត្យចំណាយសាធារណៈ( IFAPER) សាធារណៈ ។

-បានទទួលលិខិតលេខ ០៤៧/០៩ ល.អ.ជ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩ ពីអគ្គលេខាធិការ នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ស្តីពីសំណើសុំចាត់តាំងតំណាងចំនួន ០១ រូប ចូលរួមសិក្ខាសាលាស្តីពីការកែលម្អសេវា សាធារណៈក្នុងក្របខ័ណ្ឌកំណែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែង ។

-បានទទួលលិខិតលេខ ១០២០ កយ.រប/០៩ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩ ពីក្រសួងយុត្តិធម៌ ស្តីពីការចាត់តាំងមន្ត្រីចំនួន ០៦ រូប សម្រាប់គម្រោងសិទ្ធិទទួលបានយុត្តិធម៌ ។

-បានទទួលលិខិតលេខ ២៨៧ លអជ.រប ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៩ ពីទីស្តីការគណៈរដ្ឋមន្ត្រីអញ្ជើញចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធសាលាពុទ្ធិកៈសិក្សា និងដងទង់ វត្តប្រាង្គអណ្តែត ក្រោមអធិបតីភាពរបស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០ នាទី នៅវត្តប្រាង្គអណ្តែត ឃុំបឹងត្រាញ់ខាងត្បូង ស្រុកសំរោង ខេត្តតាកែវ ។

- បានទទួលលិខិត ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៩ ពី UNDP ស្តីពី Storage of UNDP assets on Ministry Premises ។

- បានទទួលលិខិតលេខ ៩៨០/០៩ កអក/គ.ជ.នា ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៩ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពីសំណើអញ្ជើញចូលរួមប្រជុំស្តីពីការពិគ្រោះតាមដាន និងត្រួតពិនិត្យរួមគ្នាលើកគម្រោងឬ កម្មវិធីអាទិភាពមួយចំនួន(Project/program Monitoring) ។

-បានទទួលលិខិតលេខ ១៩២/០៩ គ.ស.ម.ក ចុះថ្ងៃទី១០ ខែកក្កដាឆ្នាំ២០០៩ ពីគណកម្មាធិការសិទ្ធិមនុស្សកម្ពុជា ស្តីពីសំណើសុំការអនុញ្ញាតជូន ឯកឧត្តម ម៉ក់ សម្បត្តិ អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដើម្បីចូលរួមក្នុងទស្សនកិច្ចសិក្សា ស្តីពីការងារអំប៊ូស្មាន់នៅសាធារណរដ្ឋកូរ៉េខាងត្បូង ។

- បានទទួលលិខិតលេខ ២៩៦ លអជ.រប.ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំ ជាមួយគណៈប្រតិភូធនាគារពិភពលោក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិភាក្សាលើៈ

១-សេចក្តីព្រាងច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយ

២- កំណែទម្រង់រដ្ឋបាលសាធារណៈ

៣- អភិបាលកិច្ចល្អ

- បានទទួលលិខិតលេខ ១៧១៨ សជណ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩ ពីក្រសួងមហាផ្ទៃ ស្តីពីការអញ្ជើញ ឯកឧត្តម សក់ សេដ្ឋា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ដើម្បីទៅចូលរួមទស្សនកិច្ចសិក្សានៅប្រទេសកូរ៉េ ខាងត្បូង ។

- បានទទួលលិខិតលេខ ០១០/០៩ លឆត.អ.ប.អ.ព ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩ ពីអង្គភាពប្រឆាំងអំពើពុករលួយ ស្តីពីករណីសំណើសុំអនុញ្ញាតជូន ឯកឧត្តម សរ សម្បត្តិ សមាជិកប្រចាំការនៃអង្គភាពប្រឆាំង អំពើពុករលួយដើម្បីចូលរួមដំណើទស្សនកិច្ចសិក្សា ស្តីពីអំប៊ូស្មាន់នៅសាធារណៈរដ្ឋកូរ៉េ ។

- ទទួលលិខិតលេខ ៥៧០ផក.ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩ ក្រសួងផែនការស្តីពីការពិគ្រោះយោបល់ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣ (ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០០១៣ ) ដោយជូនភ្ជាប់នូវកំណត់ហេតុប្រជុំក្រុមការងារបច្ចេកទេសផែនការនិងការកាត់បន្ថយភាពក្រីក្រ (TWG-PPR ) ។

- បានទទួលលិខិតលេខ ៤៦០/គ.ម/០៩ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩ ពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការបង់ប្រាក់ភាគទានប្រចាំត្រីមាស ។

- បានទទួលលិខិតអញ្ជើញ លេខ ១០១៧/០៩ ក.អ.ក/គ.ជ.នា ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍ ក្នុងការចូលរួមរបស់ក្រុមការងារក្នុងគំនិតផ្តួចផ្តើម ស្តីពីការពង្រឹងប្រសិទ្ធភាពនៃភាពជាដៃគូកាល ពីខែមិថុនា ឆ្នាំ២០០៩ ។

- បានទទួលលិខិតលេខ ៣០៣ លអជ.រប ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ ពីទីស្តីការគណៈរដ្ឋមន្ត្រី អញ្ជើញចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាបន្តលើសេចក្តីព្រាងច្បាប់ស្តីពីអស្សាមិករណ៍ ដែលនឹង ប្រព្រឹត្តទៅនៅថ្ងៃទី២១-២២ ខែកក្កដា ឆ្នាំ២០០៩ វេលាម៉ោង ៨ៈ៣០ នាទី ។

- បានទទួលលិខិតលេខ ៣០៦ លអជ.រប ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ ពីទីស្តីការគណៈរដ្ឋមន្ត្រី អញ្ជើញចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ អគ្គលេខធិការដ្ឋាន នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទីពុធ ទី២២ ខែកក្កដា ឆ្នាំ២០០៩ វេលាម៉ោង ១៥ៈ០០ នាទី ។

- បានទទួលលិខិតចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីសំណើសុំប្រាក់បង្គ្រប់ដូរសំបុត្រយន្តហោះពីថ្នាក់ Economic ទៅថ្នាក់ Business សម្រាប់ដំណើរទស្សនកិច្ច ស្តីពីការងារអំប៊ូស្មាន់នៅសាធារណៈរដ្ឋកូរ៉េខាងត្បូងជូន ឯកឧត្តម ច័ន្ទ តានី រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និង ឯកឧត្តម ស៊ុយ ម៉ុងលាង អគ្គលេខាធិការនៃក្រុម ប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។

- បានទទួលលិខិតលេខ ៣០៤ លអជ.រប ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ ពីទីស្ដីការគណៈរដ្ឋមន្ត្រី នូវលិខិតអញ្ជើញចូលរួមអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាបន្តលើសេចក្ដី ព្រាងច្បាប់ ស្ដីពីសុំកូនអន្តរប្រទេស ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃព្រហស្បតិ៍ ទី២៣ ខែកក្កដា ឆ្នាំ២០០៩ វេលាម៉ោង ៨ៈ៣០ នាទី ។

- បានទទួលលិខិតលេខ ៦១ អនញ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ ពីទីស្ដីការគណៈរដ្ឋមន្ត្រី ស្ដីពីការអនុញ្ញាតច្បាប់ចំនួន ០៣ (បី)ខែ ជូនលោកស្រី ហ៊ឹង សុកុល មន្ត្រីអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ គិតចាប់ពីថ្ងៃទី ០១ ខែសីហា ឆ្នាំ២០០៩ ដល់ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០០៩ ដើម្បីលំហែ មាតុភាព។

- បានទទួលលិខិត លេខ ១០២៥/០៩ ក.អ.ក/គ.ជ.នា ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នូវដីការបញ្ជូនសំណើរសុំបំពេញសេចក្ដីព្រាងឯកសារគម្រោង លើកទី១(First Draft Proposal) ៖ ១- Application Format,២- Screening Format ។

- បានទទួលលិខិតពី UNDP ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ស្ដីពី Assessment of Development Result (ADR) in Cambodia ចុះ និងរបាយការណ៍ប្រចាំត្រីមាសទី១ និងត្រីមាសទី២ របស់គម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា ។

- ទទួលលិខិតលេខ ៦៤ កយ.ប្រ.ក/០៩ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ ប្រកាសស្ដីពីការបង្កើតក្រុមការងារតុលាការគំរូ របស់ក្រសួងយុត្តិធម៌ ។

- ទទួលលិខិតលេខ ៣២៤ លអជ.រប. ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ អញ្ជើញចូលរួមជាកិត្តិយស ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈ នៃការឯាគយល់គ្នា រវាងដៃគូអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាលកម្ពុជាដែលតំណាងដោយទីស្ដីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ឯកឧត្ដម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រីដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០០៩ វេលាម៉ោង ១៦ៈ០០នាទី នៅទីស្ដីការគណៈរដ្ឋមន្ត្រី។

- ទទួលលិខិតលេខ ០៥៩/០៩ លអជ. ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩ ពីអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ស្ដីពីសំណើអញ្ជើញចូលរួមប្រជុំ ដើម្បីពិភាក្សាលើការរៀបចំចងក្រងផែនការសកម្មភាព អភិបាលកិច្ចទី ៣ ការបន្តចងក្រងកម្រងព័ត៌មាន សេវាសាធារណៈ និងការពង្រឹងការគ្រប់គ្រងចំណាយថវិកាលើបៀវត្ស និងប្រាក់បំណាច់ផ្សេងៗ ។

## ខ.ការងារកំណែទម្រង់

- អគ្គលេខធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានរៀបចំកិច្ចប្រជុំផ្ទៃក្នុងកាល ពីថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩ ក្រោមអធិបតីភាពឯកឧត្ដម សួង លាងហៃ អគ្គលេខាធិការរង ដោយផ្ដោតទៅលើការធ្វើផែនការសកម្មភាព ទៅតាមក្រុមគម្រោងនីមួយៗ និងបានពិភាក្សាគ្នាអំពីបញ្ហាប្រឈមមួយចំនួនទាក់ទងទៅ នឹង ក្រុមគម្រោងទាំងប្រាំ និងបន្តការប្រជុំជាបន្តទៀតនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៩ វេលាម៉ោង ៩ៈ០០ ព្រឹក។

- អគ្គលេខធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានរៀបចំសិក្ខាសាលាស្ដីពីការធ្វើផែនការយុទ្ធសាស្ត្ររបស់អគ្គលេខធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់

និងប្រព័ន្ធយុត្តិធម៌នៅខេត្តកោះកុងរយៈពេលបីថ្ងៃ គឺ១៦-១៧ ខែកក្កដា ឆ្នាំ២០០៩ ដោយមានការចូលរួមពីដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយចូលរួមក្នុង ការពិភាក្សាធ្វើផែនការយុទ្ធសាស្រ្ត ។

- ត្រៀមរៀបចំកិចប្រជុំ ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងវិស័យតុលាការ នៅថ្ងៃទីពុធទី០៥ ខែសីហា ឆ្នាំ២០០៥ វេលាម៉ោង ០៩ៈ០០ព្រឹក។

- ត្រៀមរៀបចំប្រជុំ ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណែទម្រងច្បាប់ និងប្រព័ន្ធយុត្តិធម៌ ជាមួយដៃគូអភិវឌ្ឍន៍ និងស្ថាប័នពាក់ព័ន្ធ ដែលនឹងត្រូវធ្វើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។

- ត្រៀមរៀបចំ កិច្ចប្រជុំក្រុមប្រឹក្សាគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា ដែលនឹងប្រព្រឹត្តនៅថ្ងៃ អង្គារ៍ ទី២៥ ខែ សីហា ឆ្នាំ២០០៩ វេលាម៉ោង ២ៈ៣០ នាទី នៅសាលប្រជុំក្រសួងយុត្តិធម៌ដែលគោលបំណងនៃកិច្ចប្រជុំ ក្រុមប្រឹក្សាគម្រោងនេះ គឺដើម្បីបង្ហាញពីការរីកចម្រើននៃការអនុវត្តគម្រោងក្នុងត្រីមាសទី១ និងត្រីមាសទី២ នៃ ឆ្នាំ២០០៩ និងអំពីសំណើកែតម្រូវលើផែនការថវិកា ដើម្បីសុំការអនុម័តយល់ព្រមពីក្រុមប្រឹក្សាគម្រោង។

- ក្រុមគម្រោងនីមួយៗរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បានរៀបចំ និងធ្វើផែនការការងារសម្រាប់ឆ្នាំ២០០៩។

## គ. ផ្សេងៗ

-ចូលរួមប្រជុំអន្តរក្រសួងផ្សេងៗ

-ចូលរួមសិក្ខាសាលា ស្តីពីការកែលម្អសេវាសាធារណៈក្នុងក្របខ័ណ្ឌកំណែទម្រង់រដ្ឋបាលសាធារណៈដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែង នៅទីស្តីការគណៈរដ្ឋមន្ត្រី សាល A រយៈពេល១ថ្ងៃ ។

- រួមក្នុងកិច្ចប្រជុំ ជាមួយគណៈប្រតិភូធនាគារពិភពលោក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិភាក្សាលើៈ

១-សេចក្តីព្រាងច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយ

២- កំណែទម្រង់រដ្ឋបាលសាធារណៈ

៣- អភិបាលកិច្ចល្អ

ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩ វេលាម៉ោង ១៦ៈ០០ នាទីនៅទីស្តីការគណៈរដ្ឋមន្ត្រី។

-បានបញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ចំនួន ១រូប ទៅចូលរួមវគ្គបណ្តុះបណ្តាល ប្រព័ន្ធដោះស្រាយវិវាទនៅប្រទេសសង្ហបូរីរយៈពេល ១០ ថ្ងៃ គឺពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៩ ដល់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩។

- គណៈប្រតិភូចំនួន ១០រូប ដែលដឹកនាំដោយ ឯកឧត្តម ស៊ុយ ម៉ុងលាង អគ្គលេខាធិការនៃក្រុមប្រឹក្សា កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌បានទៅទស្សនកិច្ចសិក្សា ស្តីពីការងារអំប៊ុស្មាន់នៅសាធារណរដ្ឋកូរ៉េខាងត្បូង មានរយៈពេលបីថ្ងៃគឺចាប់ពីថ្ងៃ២៦ ខែកក្កដា ឆ្នាំ២០០៩ ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩ ។

## ២-សន្និដ្ឋាន

ក្នុងខែ កក្កដា ឆ្នាំ២០០៩ នេះអគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បានត្រៀមរៀបចំ កិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះ សម្រាប់កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ជាមួយស្ថាប័ន ពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ នេះ និងបានត្រៀមរៀបចំ កិច្ចប្រជុំក្រុមប្រឹក្សាគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា ដែលនឹងប្រព្រឹត្តនៅថ្ងៃ អង្គារ៍ទី២៥ ខែ សីហា ឆ្នាំ២០០៩ វេលាម៉ោង ២០:៣០ នាទី នៅសាលប្រជុំក្រសួងយុត្តិធម៌ ដែលគោលបំណងនៃកិច្ចប្រជុំក្រុមប្រឹក្សាគម្រោងនេះគឺ ដើម្បីបង្ហាញពីការរីកចម្រើន នៃការអនុវត្តគម្រោងក្នុងត្រីមាសទី១ និងត្រីមាសទី២ នៃឆ្នាំ២០០៩ និងអំពីសំណើកែតម្រូវលើផែនការថវិកា ដើម្បីសុំការអនុម័តយល់ព្រមពីក្រុមប្រឹក្សាគម្រោង ។

## ៣-ទិសដៅអនុវត្តក្នុងខែបន្ត

- បន្តអនុវត្តគម្រោងតុលាការគំរូ
- បន្តអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ
- បន្តអនុវត្តគម្រោងប្រព័ន្ធទិន្នន័យស្តីពីការលើកកំពស់សិទ្ធិនៅតាមមូលដ្ឋាន
- បន្តអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការជាមួយGTZ ជាពិសេសក្នុងការរៀបចំមូលដ្ឋានទិន្នន័យស្តីពី មុខងារស្ថាប័នរដ្ឋ
-ត្រៀមរៀបចំសន្និសិទជាតិស្តីពីលទ្ធផលការងារសំខាន់ៗពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៨
-ត្រៀមបញ្ជូនមន្ត្រី ១រូប នៃអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដើម្បីទៅចូលរៀនវគ្គបណ្តុះបណ្តាល ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលនៅក្នុងសេដ្ឋកិច្ចពិភពលោកនៅទីក្រុងស្តុកខុម (Stockholm) ប្រទេស ស៊ុយ អែត (Sweden) ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ ដល់ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩ ។
- ត្រៀមបញ្ជូនមន្ត្រី ១រូប នៃអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីទៅសិក្សាថ្នាក់អនុបណ្ឌិតផ្នែកច្បាប់ពាណិជ្ជកម្ម និងសេដ្ឋកិច្ចអន្តរជាតិ នៅទីក្រុងហ្វូគុយកា-កិន(Fukuoka-ken)ប្រទេសជប៉ុន(Japan)។

រាជធានី ភ្នំពេញ ថ្ងៃទី៧ ខែសីហាឆ្នាំ២០០៩
អ្នកធ្វើរបាយការណ៍

**ស៊ុន សិរីវុធ**

បានឃើញ និងឯកភាព
នាយកអង្គភាពគ្រប់គ្រងគម្រោង

**ស៊ុយ ម៉ុងលាង**